ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង
លេខ ០៥៦ / ០១០ / ២០០២
ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២

សេចក្តីសំរេច
លេខ ០៥០/០០១/២០០៣ កបធ.ច
ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ មិនា ឆ្នាំ ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញលិខិត ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០២ របស់សមាជិកសភា ១៣ រូប នៃគណបក្សសម រង្ស៊ី ជូនឯកឧត្តមប្រធាន **ម៉ិន ឈិន** ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ៣០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៦ ខែ ឆ្នាំ ដដែល ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា សមាជិកសភាចំនួន ១៣ រូប បានស្នើមកក្រុមប្រឹក្សាធម្មនុញ្ញក្នុងចំនួនលើសពីមួយភាគដប់( ១/១០ x ១២២) ឱ្យបកស្រាយមាត្រា៣០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។ សំណើនេះស្របតាមមាត្រា១៣៦ ថ្មី និងមាត្រា ១៤១ថ្មី នៃរដ្ឋធម្មនុញ្ញ ។ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចយកសំណើនេះមកពិនិត្យបាន ។
- យល់ឃើញថា ក្រុមប្រឹក្សាឃុំ សង្កាត់ ម្យ៉ាងជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន ម្យ៉ាងទៀតជាភ្នាក់ងារតំណាងរដ្ឋដែលស្ថិតនៅក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ( មាត្រា៤២ ) ។ ក្នុងឋានៈជាតំណាងប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីធំធេងក្នុងការ

បំរើកិច្ចការមូលដ្ឋាន រៀបចំសណ្តាប់ធ្នាប់សាធារណៈ សេវាសាធារណៈ ផាសុកភាព និងសុខុមាលភាព អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ថែរក្សាបរិស្ថាន ។ល។ ក្នុងក្របខ័ណ្ឌនយោបាយវិមជ្ឈការ ។ ក្នុងឋានៈជាភ្នាក់ងារតំណាងរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវគោរព និងអនុវត្តតាមការណែនាំថ្នាក់លើ តាមលំដាប់ឋានានុក្រម ។

- យល់ឃើញថា មាត្រា ៣០ ( វាក្យខណ្ឌទី ១ និងទី ២ ) នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលបានតម្រូវអោយក្រុមប្រឹក្សាឃុំ សង្កាត់រៀបចំជ្រើសរើសមេភូមិ ។ មេភូមិត្រូវរៀបចំចាត់តាំងអនុប្រធានភូមិ និងសមាជិកជាជំនួយការ ( លក្ខណៈគ្រប់គ្រាន់) បានតម្រូវយ៉ាងច្បាស់ថា (វាក្យខណ្ឌទី៣): " រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីបែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ និងការតែងតាំងជំនួយការមេភូមិ " ដែលជាបទបញ្ញត្តិមានលក្ខណៈចាំបាច់ ។ មាត្រា ៨៦ បានបញ្ជាក់បន្ថែមក្នុងអន្តរប្បញ្ញត្តិថា ត្រូវធ្វើ ... " តាមបែបបទនីតិវិធីដូច មានចែងក្នុងមាត្រា ៣០ នៃច្បាប់នេះ " ។
- យល់ឃើញថា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មិនបានកំណត់រយៈពេលឱ្យរដ្ឋមន្ត្រីក្រសួងមហាផ្ទៃចេញសេចក្តីណែនាំក្នុងរឿងនេះទេ ប៉ុន្តែការពិនិត្យបានបង្ហាញឱ្យឃើញថា មានការកំណត់រយៈពេលសម្រាប់រឿងផ្សេង១ឯទៀត មានយ៉ាងយូរត្រឹម ០៦ ខែ ។ ការពិនិត្យបន្ថែមបានបង្ហាញឱ្យឃើញថា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានតម្រូវឱ្យក្រសួងមហាផ្ទៃចេញសេចក្តីណែនាំចំនួនប្រហែលម្ភៃ សំរាប់បង្កើនប្រសិទ្ធភាពនៃនយោបាយវិមជ្ឈការនេះ ។
- យល់ឃើញថា " គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ " ដែលមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន បង្កើតដោយមាត្រា៨៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ក្នុងគោលដៅបង្កលក្ខណៈសម្បត្តិងាយស្រួលដល់នយោបាយវិមជ្ឈការមានសមត្ថកិច្ចគ្រប់គ្រាន់ ( មាត្រា ៨៨ ) ក្នុងការដោះស្រាយ ឬជំរុញអោយមានការណែនាំក្នុងរយៈពេលសមស្របមួយ ។
- យល់ឃើញថា តាមមាត្រា ៤៤ ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងឋានៈជាភ្នាក់ងាររដ្ឋ អាចត្រូវបានទទួលប្រតិភូកម្មអំណាចពីសំណាក់អាជ្ញាធររដ្ឋសំរាប់កិច្ចការអនុវត្តន៍ផ្សេងៗលែងតែវិស័យដែលមានចែងច្បាស់ក្នុងមាត្រា ៤៥ ដែលជាសមត្ថកិច្ចរបស់អាជ្ញាធរកណ្តាល ។
- យល់ឃើញថា ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងឋានៈជាភ្នាក់ងារតំណាងរដ្ឋត្រូវស្នើសុំការណែនាំគោលការណ៍នៃការរៀបចំជ្រើសរើសមេភូមិពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទោះបីក្នុងលក្ខណៈជាការជ្រើសរើសបណ្តោះអាសន្នក៏ដោយ ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានកាតព្វកិច្ចត្រូវឆ្លើយតបចំពោះសំណូមពរនេះក្នុងរយៈពេលមួយសមស្រប ។

**សំរេច**

**មាត្រា ១ :** មាត្រា ៣០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវបកស្រាយតាមមូលបទខាងលើនេះ ។

**មាត្រា ២ :** សេចក្តីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០០៣

ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ប៊ិន ឈិន